ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំសិង្ហបុរី

លេខ: 353 សកសប

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** របាយការណ៍ស្តីពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្មអមស្ថានទូតកម្ពុជាប្រចាំសិង្ហបុរីប្រចាំខែ តុលា-វិច្ឆិកា ឆ្នាំ២០១២។

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសសូមជាក់ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបនូវរបាយការណ៍ស្តីពីសកម្មភាពការងាររបស់អនុព័ន្ធពាណិជ្ជកម្មអមស្ថានទូតកម្ពុជាប្រចាំសិង្ហបុរីប្រចាំខែ តុលា-វិច្ឆិកា ឆ្នាំ២០១២ ដូចខាងក្រោម:

-កាលពីថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ បានចូលរួមកម្មវិធី Mexico-Asia Infrastructure Finance Summit ដែលរួមគ្នារៀបចំឡើងដោយស្ថានទូតប្រទេសម៉ិកស៊ិច និង World Bank Global Infrastructure Finance Center of Excellence នៅប្រទេសសិង្ហបុរី និងដោយមានកិច្ចសហប្រតិបត្តិការរបស់សហគ្រាសអន្តរជាតិសិង្ហបុរី (IE Singapore) ។

-កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ បានចូលរួមកម្មវិធី Singapore Insights: City in a Garden ដែលរៀបចំឡើងដោយ Singapore International Foundation។

-កាលពីថ្ងៃទី ១៩-២០ ខែ តុលា ឆ្នាំ ២០១២ បានចូលរួមរៀបចំពិព័រណ៍ទេសចរណ៍ IBT ២០១២ ដែលប្រព្រឹត្តទៅនៅ Marina Bay Sands Convention & Exhibition Center។ ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍កម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមពិព័រណ៍ខាងលើដែលមានសមាសភាពមកពីក្រសួងទេសចរណ៍សណ្ឋាគារ និងទីភ្នាក់ងារទេសចរណ៍ ដើម្បីដាក់តាំងបង្ហាញពីសក្តានុពល និងតំបន់ទេសចរណ៍ដែលទាក់ទាញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-កាលពីថ្ងៃទី ២៤-២៥ ខែ តុលា ឆ្នាំ ២០១២ បានចូលរួមកិច្ចប្រជុំកំពូលសហគ្រិនសកលសិង្ហបុរី ២០១២ (GES 2012) ដោយរួមគ្នារៀបចំដោយគណៈកម្មាធិការអភិវឌ្ឍន៍សេដ្ឋកិច្ចសិង្ហបុរី និងសហព័ន្ធពាណិជ្ជកម្មសិង្ហបុរី និងគាំទ្រដោយសហគ្រាសអន្តរជាតិសិង្ហបុរី (IE Singapore) ទីភ្នាក់ងារអភិវឌ្ឍន៍សហគ្រាស (SPRING) ដោយឯកឧត្តម LIM Hng Kiang រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាកម្មសិង្ហបុរីបានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស។

-កាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ បានចូលរួមកម្មវិធី ASEAN-Hong Kong Business Forum ដែលរៀបចំឡើងដោយការិយាល័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច ហុងកុងប្រចាំនៅប្រទេសសិង្ហបុរី។

-កាលពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានចូលរួមកម្មវិធីសម្ពោធពិព័រណ៍ Franchising & Licensing Asia (FLAsia) 2012 លើកទី ៧ ដែលមានឯកឧត្តម LEE Yi Shyan រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម សិង្ហបុរី អញ្ជើញចូលរួមជាភ្ញៀវកិត្តិយស។

-កាលពីថ្ងៃទី ០៦-០៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានចូលរួម Singapore International Technical and Vocational Education and Training (TVET) Conference 2012 ដែលរៀបចំឡើងដោយវិទ្យាស្ថានអប់រំបច្ចេកទេសសិង្ហបុរី ក្រោមការឧបត្ថម្ភរបស់ មូលនិធិ Temasek ដោយមានការចូលរួមជាកិត្តិយសរបស់ឯកឧត្តម TEO Chee Hean ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសម្របសម្រួលផ្នែកសន្តិសុខជាតិ និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃសិង្ហបុរី។



Address : 400 Orchard Road, # 10-03/04, Orchard Tower, Singapore 238875
Website : http://home.pacific.net.sg/~recambodia.sg
Tel: (65) 63419785 , Fax: (65) 63419201
E-mail: cambodiaembasy@pacific.net.sg

-កាលពីថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Masahiro Okada ជំនួយការអ្នកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន Hitachi Metals Ltd ដែលមានទីតាំងនៅប្រទេសជប៉ុន ដើម្បីស្វែងយល់ពីស្ថានភាពផ្គត់ផ្គង់អគ្គិសនី សក្តានុពលនៃការវិនិយោគ និង ពាណិជ្ជកម្ម នៅប្រទេសកម្ពុជា។

-កាលពីថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានចូលរួមរៀបចំកម្មវិធី ASEAN Gala Night ដោយបានដាក់តាំងបង្ហាញនូវឧបករណ៍ប្រពៃណី ឯកសារវិនិយោគ និង ទេសចរណ៍ របស់ប្រទេសកម្ពុជា ដើម្បីឲ្យភ្ញៀវដែលអញ្ជើញចូលរួមបានទស្សនា និង ស្វែងយល់។

-កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានជួបពិភាក្សាការងារជាមួយ លោក Eric Foo នាយកគ្រប់គ្រង នៃក្រុមហ៊ុន Sheng Ye International Pte Ltd ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ដែលមានបំណងស្វែងយល់ពីទីផ្សារពលកម្មរបស់ប្រទេសកម្ពុជា និងលទ្ធភាពផ្គត់ផ្គង់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស។

-កាលពីថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ បានចូលរួមកម្មវិធីថ្ងៃសហគមន៍សាកល ២០១២ (Global Community Day 2012) ដែលរៀបចំឡើងសាលាពហុបច្ចេកវិទ្យា Temasek (Temasek Polytechnic)។ កម្មវិធីថ្ងៃសហគមន៍សាកល ២០១២ មានការដាក់តាំងបង្ហាញពីប្រពៃណី វប្បធម៌ និង ទេសចរណ៍របស់ប្រទេសនីមួយៗ ដោយមានការចូលរួមពីស្ថានទូតប្រ៊ុយណេ ហ្វីលីពីន វៀតណាម ថៃ ស្រីលង្កា ជប៉ុន Kazakhstan អង់គ្លេស ទួរគី Saudi Arabia Venezuela អេស្ប៉ាញ និង ស្វីស។ ដោយឡែកស្ថានទូតកម្ពុជាបានរៀបចំតាំងបង្ហាញនូវឧបករណ៍ភ្លេងប្រពៃណី អង្រឹត ទ្រូ ល្បី ឯកសារវិនិយោគ និង ពាណិជ្ជកម្ម ទេសចរណ៍ និង រូបភាពគោលដៅទេសចរណ៍ ដើម្បីឲ្យទស្សនិកជនបានយល់ពីប្រពៃណី ទំនៀមទំលាប់ និង វិស័យទេសចរណ៍របស់ប្រទេសកម្ពុជាផងដែរ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

**បានឃើញ និង ឯកភាព**
**គោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
សិង្ហបុរី, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២
**ឯកអគ្គរាជទូត**

**ស៊ិន សិរី**

សិង្ហបុរី, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២
អនុព័ន្ធពាណិជ្ជកម្ម

ម៉ៅ សាកល

***ចម្លងជូន:***
-ក្រសួងពាណិជ្ជកម្ម
-ឯកសារ - កាលប្បវត្តិ